HEALTHIER, LONGER, BETTER LIVES

# Family Allowance RIDER



While our lives are full of commitment, we can't predict the future. This is why it's critical to ensure our loved ones will always be cared for and not suffer from any financial stress in case we are not around.

**Family Allowance Rider** is designed to safeguard your family's living expenses in your absence. It is an extra protection to ensure your family will be financially secured by paying them additional annual allowance equals to 100% of Rider Sum Assured starting from the Policy Anniversary immediately following the Death or Total and Permanent Disability of the Insured until the end of the coverage term.

# Summary Benefits:

## This Rider is specifically designed to offer:

| Type of Coverage | of Rider Sum Assured |
|---|---|
| **Family Allowance Benefit**<br>(Additional annual financial support following Death/Total and Permanent Disability event) | 100%<br>(As stated on the Certificate of Insurance) |

### Eligible Entry Age

18-60 years old

### Maximum Expiry Age

70 years old

### Coverage Term

Follow the coverage term of Basic Policy which it is attached to, subject to the maximum expiry age of 70 years old.

### Premium Payment Term

Follow the premium payment term of Basic Policy which it is attached to.

### Rider Sum Assured

- Minimum: US$500
- Maximum: 50% of Basic Sum Assured

# EXCLUSIONS

This Rider shall not cover any 1 (one) of the following occurrences:

1. death is due to suicide, self-inflicted injury, whether sane or insane, within 2 (two) years from the Effective Date or Commencement Date, whichever is later; or
2. death is due to Human Immunodeficiency Virus (HIV) and/or any HIV-related illnesses including Acquired Immune Deficiency Syndrome (AIDS) and/or any mutations, derivation or variations thereof; or
3. death or Total and Permanent Disability due to a criminal offence committed or attempted to commit by You, or the Insured, or the Beneficiary; or
4. death or Total and Permanent Disability due to drugs or stimulators or alcohol abuse, drunk driving, or their complications as determined by the law in force such as Law on Land Traffic, and Law on the Control of Drug, etc; or
5. Total and Permanent Disability resulting from wilful exposure to danger or attempted self-destruction or self-inflicted injuries while sane or insane;
6. Total and Permanent Disability resulting from service in the armed forces in time of declared or undeclared war or while under orders for warlike operations or restoration of public order;
7. Total and Permanent Disability resulting from entering, exiting, operating, servicing, or being transported by any aerial device or conveyance except when the Insured is a fare-paying passenger or crew member on a commercial passenger airline on a regular scheduled passenger trip over its established passenger route; or
8. Total and Permanent Disability resulting from a physical or mental condition which existed before the Effective Date or Commencement Date, whichever is later, which was not disclosed in the application or health statement.

# Example

Mr. **Samnang Laor** is a 35-year-old married male with a child of 5-year-old. He has already planned on his child's education fund for university with AIA **សម្រាប់កូន** with Basic Sum Assured of US$20,000 and coverage term of 17 years.

In addition to the education fund, his child and family's future livelihood are also very important. He would like to ensure his family's living won't be affected by a loss of income if he is not around. So, Mr. **Samnang Laor** decides to add an extra protection with Family Allowance Rider with Sum Assured of US$4,000 that could help secure the family need and necessary expenses in his absence.

Benefits obtained by Mr. **Samnang Laor** and his family:

- **Scenario 1:** Mr. **Samnang Laor** is the main insured and becomes total and permanent disabled during the policy term

Mr. **Samnang Laor** will get annual benefit of US$4,000 until end of coverage term.

- **Scenario 2:** Mr. **Samnang Laor** is the main insured and passed away during the policy term

Mr. **Samnang Laor**'s family will get annual benefit of US$4,000 until end of coverage term.

The diagram below illustrates the benefit payments if unfortunate event happens to Mr. **Samnang Laor** at 44-year-old



**HEAD OFFICE**
12TH FLOOR, EXCHANGE SQUARE, STREET 106-61, SANGKAT WAT PHNOM, KHAN DAUN PENH, PHNOM PENH

**PHNOM PENH BRANCH**
8TH & 9TH FLOOR, CITY TOWER, #321, MAO TSE TOUNG BLVD, SANGKAT PHSAR DEPO 1, KHAN TOUL KORK, PHNOM PENH

**SIEM REAP BRANCH**
#29 & 30, CHARLES DE GAULLE ROAD SALA KANSENG, SANGKAT SVAY DONGKOM, SIEM REAP

**BATTAMBANG BRANCH**
HOUSE NO. 2-6, STREET 3, PHUM KAMMEAKAR, SANGKAT SVAY POR, KRONG BATTAMBANG, BATTAMBANG

**KAMPONG CHAM BRANCH**
VILLAGE 15, SANGKAT KAMPONG CHAM, KHAN KAMPONG CHAM, KAMPONG CHAM

**KAMPOT BRANCH**
STREET 700, VILLAGE 1 OSSAPHEA, SANGKAT KAMPONG KANDAL, KRONG KAMPOT, KAMPOT

086 999 242 | AIA.COM.KH | AIA CAMBODIA

សុខភាព និងជីវិត
កាន់តែប្រសើរ

# ផលិតផលធានារ៉ាប់រងបន្ថែមលើ
# ប្រាក់ឧបត្ថម្ភគ្រួសារ



ជីវិតរបស់យើងពោរពេញទៅដោយការតាំងចិត្ត ខណៈពេលអនាគតគឺយើងមិនអាចដឹងទុកជាមុន។ យើងគួរមានគម្រោងរៀបចំផែនការហិរញ្ញវត្ថុជាមុន ដើម្បីធានាថាមនុស្សជាទីស្រលាញ់របស់យើងនឹងតែងតែត្រូវបានយកចិត្តទុកដាក់ជានិច្ច ហើយនឹងមិនទទួលរងបន្ទុកហិរញ្ញវត្ថុនៅពេលអ្នកមិននៅក្បែរ។

**ផលិតផលធានារ៉ាប់រងបន្ថែមលើប្រាក់ឧបត្ថម្ភគ្រួសារ** ត្រូវបានរចនាឡើងដើម្បីទំនុកបម្រុងលើចំណាយក្នុងការរស់នៅរបស់គ្រួសារអ្នក និងជួយលើបញ្ហាប្រឈមនឹងការបាត់បង់ប្រាក់ចំណូលសម្រាប់គ្រួសារអ្នក នៅពេលអវត្តមានរបស់អ្នក។ វាជាការការពារបន្ថែមដើម្បីធានាថា គ្រួសាររបស់អ្នកនឹងត្រូវបានការពារផ្នែកហិរញ្ញវត្ថុ និងទទួលបានប្រាក់ចំណូលប្រចាំឆ្នាំបន្ថែមស្មើនឹង 100% នៃទឹកប្រាក់ធានារ៉ាប់រងនៃផលិតផលធានារ៉ាប់រងបន្ថែម ដែលនឹងត្រូវផ្តល់ជូនចាប់ពីខួបនៃបណ្ណសន្យារ៉ាប់រងនៅឆ្នាំបន្ទាប់ ក្រោយពេលអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ រហូតដល់ចុងបញ្ចប់នៃរយៈពេលនៃការធានារ៉ាប់រង។

## អត្ថប្រយោជន៍សង្ខេបស្តីពីផលិតផលធានារ៉ាប់រងបន្ថែម៖

ផលិតផលធានារ៉ាប់រងបន្ថែមលើប្រាក់ឧបត្ថម្ភគ្រួសារ ផ្តល់ជូនជាមួយនឹងលក្ខណៈពិសេសដូចជា៖

| ប្រភេទអត្ថប្រយោជន៍ធានារ៉ាប់រង | នៃទឹកប្រាក់ធានារ៉ាប់រងនៃផលិតផលធានារ៉ាប់រងបន្ថែម |
|---|---|
| **អត្ថប្រយោជន៍លើប្រាក់ឧបត្ថម្ភគ្រួសារ** (ការការពារបន្ថែមលើប្រាក់ចំណូលប្រចាំឆ្នាំក្នុងករណីទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍) | 100% (ដូចបានកំណត់លើវិញ្ញាបនបត្រធានារ៉ាប់រង) |

### អាយុដែលត្រូវបានអនុញ្ញាតទទួលយកការធានារ៉ាប់រង
18-60 ឆ្នាំ

### អាយុដែលត្រូវបានការពារអតិបរមា
70 ឆ្នាំ

### រយៈពេលនៃការធានារ៉ាប់រង
អនុលោមតាមរយៈពេលនៃការធានារ៉ាប់រងសម្រាប់បណ្ណសន្យារ៉ាប់រងមូលដ្ឋាន ដែលភ្ជាប់ជាមួយ ដោយផ្តល់ការធានារហូតដល់អ្នកត្រូវបានធានារ៉ាប់រងមានអាយុគ្រប់ 70 ឆ្នាំ។

### រយៈពេលនៃការបង់បុព្វលាភធានារ៉ាប់រង
អនុលោមតាមរយៈពេលនៃការធានារ៉ាប់រងសម្រាប់បណ្ណសន្យារ៉ាប់រងមូលដ្ឋានដែលភ្ជាប់ជាមួយ។

### ទឹកប្រាក់ធានារ៉ាប់រងនៃផលិតផលធានារ៉ាប់រងបន្ថែម៖
- អប្បបរមា : US$500
- អតិបរមា : 50% នៃទឹកប្រាក់ធានារ៉ាប់រងមូលដ្ឋាន

# ករណីមិនធានា

ផលិតផលធានារ៉ាប់រងបន្ថែមនេះ មិនធានាករណីណាមួយនៃការកើតឡើងដូចខាងក្រោមនេះ៖

1. ទទួលមរណភាពដោយការធ្វើអត្តឃាត ការធ្វើឲ្យរបួសខ្លួនឯង ទោះបីស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតី កំឡុងពេល 2 (ពីរ) ឆ្នាំចាប់ពីកាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទដែលចូលជាធរមាន ដោយយកកាលបរិច្ឆេទចុងក្រោយគេ ឬ
2. ទទួលមរណភាពដោយសារវីរុសហ៊ីវ និង/ឬជំងឺណាមួយដែលជាប់ទាក់ទងនឹងវីរុសហ៊ីវ រួមទាំងជំងឺអេដស៍ និង/ឬការផ្លាស់ប្តូរ ការវិវឌ្ឍន៍ ឬការប្រែប្រួលនៃមេរោគអេដស៍ និង/ឬជំងឺដែលជាប់ទាក់ទងនឹងវីរុសហ៊ីវ រួមទាំងជំងឺអេដស៍ ឬ
3. ទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ដោយការប្រព្រឹត្ត ឬការប៉ុនប៉ងប្រព្រឹត្តនូវបទល្មើសព្រហ្មទណ្ឌ ដោយអ្នក ឬដោយអ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផល ឬ
4. ទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ដោយការប្រើប្រាស់គ្រឿងញៀន ឬថ្នាំសប្បាយ ការសេពគ្រឿងស្រវឹងហួសកម្រិត ឬបើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ដូចមានចែងនៅក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន ដូចជា ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ល។ ឬ
5. ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ពីការប្រឈមនឹងគ្រោះថ្នាក់ដោយចេតនា ឬប៉ុនប៉ងធ្វើបាបខ្លួនឯងដោយចេតនា ឬធ្វើឲ្យរបួសខ្លួនឯងទោះស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ ឬ
6. ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ពីការចូលបម្រើក្នុងជួរកងទ័ព ក្នុងកំឡុងពេលមានប្រកាស ឬគ្មានប្រកាសសង្គ្រាមក្តី ឬក្រោមបញ្ជាប្រតិបត្តិការសង្គ្រាម ឬការស្តារសណ្តាប់ធ្នាប់សាធារណៈ ឬ
7. ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ពីការធ្វើដំណើរចូល ការចាកចេញ ការធ្វើប្រតិបត្តិការ ការផ្តល់សេវា ឬត្រូវបានបញ្ជូនដោយយាន ឬមធ្យោបាយធ្វើដំណើរតាមផ្លូវអាកាស លើកលែងតែក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងគឺជាអ្នកដំណើរធម្មតា ឬអ្នកបម្រើលើយន្តហោះនៃក្រុមហ៊ុនអាកាសចរណ៍ណាមួយ ដែលធ្វើការជាប្រចាំតាមកាលវិភាគនៃអ្នកធ្វើដំណើររបស់ក្រុមហ៊ុនអាកាសចរណ៍ និងតាមគន្លងផ្លូវអាកាសសម្រាប់អ្នកធ្វើដំណើរតាមផ្លូវអាកាស ឬ
8. ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ដែលបណ្តាលមកពីបញ្ហាផ្លូវកាយ ឬផ្លូវចិត្ត ដែលកើតមានមុនកាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រងរបស់អ្នកត្រូវបានធានារ៉ាប់រង ហើយដែលមិនបានបង្ហាញក្នុងពាក្យស្នើសុំ ឬរបាយការណ៍សុខភាព។

# ឧទាហរណ៍

លោក **សំណាង ល្អ** អាយុ 35ឆ្នាំ មានកូនម្នាក់អាយុ 5ឆ្នាំ ។ គាត់បានរៀបចំផែនការហិរញ្ញវត្ថុការសិក្សារបស់កូនគាត់ដើម្បីបន្តការសិក្សានៅសាកលវិទ្យាល័យជាមួយនឹងគម្រោងធានារ៉ាប់រង AIA សម្រាប់កូន ជាមួយទឹកប្រាក់ធានារ៉ាប់រងមូលដ្ឋានចំនួន US$20,000 និងរយៈពេលនៃការធានារ៉ាប់រង 17 ឆ្នាំ។

បន្ថែមពីលើគម្រោងធានារ៉ាប់រងលើការសិក្សា ការរស់នៅជាប្រចាំរបស់កូនគាត់ក៏មានសារៈសំខាន់ណាស់ដែរ។ គាត់ចង់ធានាថាគ្រួសាររបស់គាត់ នឹងមិនប្រឈមនឹងបញ្ហាផ្នែកហិរញ្ញវត្ថុណាមួយក្នុងករណីដែលគាត់មិននៅក្បែរ។ ដូច្នេះ លោក **សំណាង ល្អ** សម្រេចចិត្តបន្ថែមការការពារនៃផលិតផលធានារ៉ាប់រងបន្ថែមលើប្រាក់ឧបត្ថម្ភគ្រួសារ ជាមួយទឹកប្រាក់ធានារ៉ាប់រងសរុបចំនួន US$4,000 ដែលអាចជួយទំនុកបម្រុងដល់តម្រូវការគ្រួសារនិងការចំណាយចាំបាច់នៅពេលអវត្តមានរបស់គាត់។

### អត្ថប្រយោជន៍ដែលលោក **សំណាង ល្អ** និងក្រុមគ្រួសារនឹងទទួលបាន៖

- ករណីទី 1: ប្រសិនបើលោក **សំណាង ល្អ** ដែលជាអ្នកត្រូវបានធានារ៉ាប់រងគោល ទទួលពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ក្នុងកំឡុងពេលនៃការធានារ៉ាប់រង

លោក **សំណាង ល្អ** នឹងទទួលបានទឹកប្រាក់ធានារ៉ាប់រងប្រចាំឆ្នាំ US$4,000 រហូតដល់ចុងបញ្ចប់នៃរយៈពេលនៃការធានារ៉ាប់រងនៃផលិតផលធានារ៉ាប់រងបន្ថែម។

- ករណីទី 2: ប្រសិនបើលោក **សំណាង ល្អ** ដែលជាអ្នកត្រូវបានធានារ៉ាប់រងគោល ទទួលមរណភាពក្នុងកំឡុងពេលនៃការធានារ៉ាប់រង

គ្រួសាររបស់លោក **សំណាង ល្អ** នឹងទទួលបានទឹកប្រាក់ធានារ៉ាប់រងប្រចាំឆ្នាំ US$4,000 រហូតដល់ចុងបញ្ចប់នៃរយៈពេលនៃការធានារ៉ាប់រងនៃផលិតផលធានារ៉ាប់រងបន្ថែម។

រូបភាពខាងក្រោមបង្ហាញអំពីការផ្តល់ជូនអត្ថប្រយោជន៍ ក្នុងករណីមានគ្រោះអកុសលកើតឡើងចំពោះលោក **សំណាង ល្អ** ក្នុងវ័យ 44 ឆ្នាំ



**ការិយាល័យកណ្ដាល**

ជាន់ទី 12 អគារ EXCHANGE SQUARE

ផ្លូវលេខ 106 កែងផ្លូវលេខ 61 សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

**សាខាភ្នំពេញ**

ជាន់ទី 8 និងទី 9 អគារ CITY TOWER

លេខ 321 មហាវិថីម៉ៅសេទុង សង្កាត់ផ្សារដេប៉ូ 1 ខណ្ឌទួលគោក រាជធានីភ្នំពេញ

**សាខាសៀមរាប**

អគារលេខ 29 និង 30

ផ្លូវហ្សាលដឺហ្គោល សាលាកន្សែង សង្កាត់ស្វាយដង្គំ ទីរួមខេត្តសៀមរាប

**សាខាបាត់ដំបង**

ផ្ទះលេខ 2-6ផ្លូវលេខ 3 ភូមិកម្មករ សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង

**សាខាកំពង់ចាម**

ភូមិ 15 សង្កាត់កំពង់ចាម ខណ្ឌកំពង់ចាម ខេត្តកំពង់ចាម

**សាខាកំពត**

ផ្លូវលេខ 700 ភូមិ 1ឧសភា សង្កាត់កំពង់កណ្ដាល ក្រុងកំពត ខេត្តកំពត

086 999 242 | AIA.COM.KH | AIA CAMBODIA